ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
លេខាធិការដ្ឋាន គ.ជ.អ.ប

អង្គភាពត្រួតពិនិត្យ វាយតម្លៃ និង ព័ត៌មាន

លេខ:.....១៣៨............../អតវ

រាជធានីភ្នំពេញ, ថ្ងៃទី...២៨...ខែ..មិថុនា..ឆ្នាំ២០១៥

**សូមគោរពជូន**

**ឯកឧត្តមអនុប្រធានប្រចាំការលេខាធិការដ្ឋានគ.ជ.អ.ប**

**កម្មវត្ថុ៖** របាយការណ៍ចុះត្រួតពិនិត្យការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមនៅខេត្តស្វាយរៀង ខេត្តត្បូងឃ្មុំ និងខេត្តព្រៃវែង។

**យោង៖** លិខិតបេសកកម្មលេខ ១៦៣ បសក/គ.ជ.អ.ប ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៥ របស់លេខាធិការដ្ឋានគ.ជ.អ.ប។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា៖ ក្រុមការងារអនុវត្តគណនេយ្យភាពសង្គមនៃលេខាធិការដ្ឋានគ.ជ.អ.ប ដែលរួមមាន៖

| | |
|---|---|
| ១. លោក ជេដ្ឋ គឹមជុង | អនុប្រធានអង្គភាពត្រួតពិនិត្យវាយតម្លៃ និងព័ត៌មាន |
| ២. លោក លី យ៉ាសាក់ | មន្ត្រីត្រួតពិនិត្យ របាយការណ៍ និងបណ្តុះបណ្តាល |
| ៣. លោក ចន្ទី សុមេត្តា | មន្ត្រីព័ត៌មាន |

បានចុះបេសកកម្ម ដើម្បីត្រួតពិនិត្យមើលការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម ចាប់ពីថ្ងៃទី២៣-២៦ ខែមិថុនា ឆ្នាំ២០១៥ក្នុងស្រុកគោលដៅចំនួន៣គឺស្រុករមាសហែក ស្រុកពាមរក៍ និងស្រុកអូររាំងឪ ស្ថិតក្នុងខេត្តចំនួន៣គឺខេត្តស្វាយរៀង ខេត្តព្រៃវែង និងខេត្តត្បូងឃ្មុំ។

## ក. គោលបំណងជាក់លាក់នៃបេសកម្ម

- ពិនិត្យមើលដំណើរការនៃការអនុវត្តគណនេយ្យភាពសង្គមរបស់ផ្នែកផ្គត់ផ្គង់
- វាយតម្លៃនូវចំណេះដឹងរបស់អ្នកផ្តល់សេវាក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម
- កំណត់បញ្ហាដែលកើតឡើងក្នុងការអនុវត្ត និងលើកជាអនុសាសន៍ជូនថ្នាក់ដឹកនាំពិនិត្យសម្រេចក្នុងការជំរុញ និងលើកកម្ពស់ប្រសិទ្ធភាពការអនុវត្ត។

## ខ. ដំណើរការនៃបេសកកម្ម

ក្នុងដំណើរបេសកកម្មក្រុមការងារបានជួបប្រជុំជាមួយផ្នែកផ្គត់ផ្គង់ដែលរួមមានរដ្ឋបាលស្រុកទាំង បី ដែលបានរាប់ខាងលើ ក្រុមប្រឹក្សាឃុំ តំណាងមណ្ឌលសុខភាព និងតំណាងបឋមសិក្សាគោលដៅដែលមានទីតាំងក្នុងស្រុកទាំងបី ដែលផ្តោតលើការយល់ដឹងជារួមលើដំណើរការអនុវត្ត I-SAF ដែលរួមមានដំណើរការប្រមូលទិន្នន័យ ការផ្សព្វផ្សាយព័ត៌មាន ដំណើរការនៃការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និងការអនុវត្តផែនការគណនេយ្យភាពសង្គមរួម ។ ជាមួយគ្នានេះដែរ ក្រុមការងារក៏បានចុះផ្ទាល់ពិនិត្យមើលការបិទផ្សាយផ្ទាំងរូបភាពកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋផងដែរ។

គ. លទ្ធផលសង្ខេប

សូមគោរពជម្រាបជូន ឯកឧត្តម មេត្តាជ្រាបថា៖ ក្នុងវដ្តនៃការអនុវត្តផែនយុទ្ធសាស្ត្រគណនេយ្យភាពសង្គមប្រចាំឆ្នាំ សកម្មភាពចម្បងៗរួមមាន៖

១. ការបង្ហាញពីព័ត៌មាននានា (ចាប់ពីខែមករា ដល់ខែ មេសា)៖ ចំនុចនេះផ្តោតសំខាន់លើការបង្ហាញព័ត៌មានដល់ប្រជាពលរដ្ឋតាមរយៈផ្ទាំងរូបភាពកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs)។

២. ដំណើរត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ (ចាប់ពីខែឧសភា និងខែកញ្ញា)៖ ផ្តោតលើការវាយតម្លៃរបស់ប្រជាពលរដ្ឋទៅលើការផ្តល់សេវារបស់រដ្ឋបាលឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សា និងរៀបចំផែនការរួមគ្នា

៣. ដំណើរការកសាងផែនការដែលមានស្រាប់៖ ផ្តោតទៅលើការអនុវត្តផែនការគណនេយ្យភាពសង្គមរួម (JAAP)

១.) អំពីការបង្ហាញពីព័ត៌មាននានា

➢ ការអនុវត្តក្នុងស្រុករមាសហែក ខេត្តស្វាយរៀង និងស្រុកអូរាំងឪ ខេត្តកំពង់ចាម

- ដំណើរការប្រមូលទិន្នន័យ និងផលិត Post-On

ជាគោលការណ៍នៃការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម រដ្ឋបាលស្រុកមានតួនាទីជាអ្នកប្រមូលទិន្នន័យពីរដ្ឋបាលឃុំ សាលាបឋមសិក្សា និងមណ្ឌលសុខភាព ដើម្បីផលិត Post-On រួច បញ្ជូនត្រលប់មកសេវាទាំងបីដែលបានរៀបរាប់ខាងលើវិញ ដើម្បីបិទផ្សាយ។ តែអ្នកផ្តល់សេវាទាំងបី ហាក់ដូចជាមិនដឹងច្បាស់ថាការប្រមូលទិន្នន័យនេះ ធ្វើឡើងក្នុងគោលបំណងអ្វីឡើយ។ គឺផ្តល់ទិន្នន័យតាមតម្រូវការរបស់ថ្នាក់ស្រុកប៉ុណ្ណោះ។

ម្យ៉ាងវិញទៀត រដ្ឋបាលស្រុករមាសហែក ខេត្តស្វាយរៀង និងរដ្ឋបាលស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ មិនទាន់បានរៀបចំដំណើរការប្រមូលព័ត៌មាន និងផលិតព័ត៌មានលើផ្ទាំងPost-On សម្រាប់ឆ្នាំ២០១៥ ដើម្បីបែងចែកទៅឲ្យឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សា ធ្វើការបិទផ្សាយនៅឡើយទេរហូតមកដល់ពេលនេះ គឺមានតែព័ត៌មានឆ្នាំចាស់ ពោលគឺPost-On ដែលប្រើប្រាស់ព័ត៌មានឆ្នាំ២០១៣។ ម្យ៉ាងវិញទៀត Post-On ដែលបានផលិតក្នុងឆ្នាំកន្លងមកនេះនៅមានបញ្ហាបច្ចេកទេស ដោយសារនៅមានជាប់ជាភាសារអង់គ្លេស។ សូមមើលរូបភាពខាងក្រោម៖




*នេះគឺជា Post-On ដែលបានបញ្ចេញពីប្រព័ន្ធទិន្នន័យ ដែលបានរៀបចំដោយរដ្ឋបាលស្រុកអូរាំងឪ ហើយត្រូវបានយកទៅបិទលើផ្ទាំងកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4Cs)ត្រូវបានផលិតចេញជាភាសាអង់គ្លេសទៅវិញ ដែលធ្វើឲ្យប៉ះពាល់ដល់ការយល់ដឹងរបស់ប្រជាពលរដ្ឋនៅសហគមន៍។ ម្យ៉ាងវិញទៀត ទិន្នន័យដែលបិទនោះ ជាទិន្នន័យឆ្នាំ២០១៣ ដែលមិនមានបច្ចុប្បន្នភាព។ Post-On នេះគឺបានបិទនៅ សាលាឃុំអំពិលតាពក ក្នុងស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ ដែលបង្ហាញពីការបំពេញភារកិច្ចរបស់ឃុំធៀប ទៅនឹងស្តង់ដាភារកិច្ចរបស់រដ្ឋបាលឃុំ ។*

- **ទីតាំងនៃការបិទផ្សាយ I4Cs**

លើសពីបញ្ហាដែលបានរៀបរាប់ខាងលើ ក្រុមការងារក៏បានសង្កេតឃើញថាគ្រប់ផ្ទាំង I4Cs ទាំងអស់គឺត្រូវបានបិទតែនៅទីតាំងសាលាឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សាប៉ុណ្ណោះ ព័ត៌មានមិនត្រូវបានផ្សព្វផ្សាយនៅទីប្រជុំជនផ្សេងទៀតឡើយ ដែលធ្វើឲ្យការផ្សព្វផ្សាយនេះហាក់ដូចជាមិនសូវបានទូលំទូលាយនៅឡើយ។ ប៉ុន្តែបញ្ហានេះត្រូវបានមើលឃើញថាមិនមែនមកពីអ្នកផ្តល់សេវាទាំងបីមិនហ៊ានផ្សព្វផ្សាយព័ត៌មានឲ្យបានទូលំទូលាយនោះគឺបណ្តាលមកពីចំនួន I4Cs មានចំនួនកំណត់។

- **ការយល់ដឹងអំពីការអនុវត្តវដ្តគណនេយ្យភាពសង្គម**

អ្នកអនុវត្តគណនេយ្យភាពសង្គមនៅរដ្ឋបាលឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សានៅមានភាពមិនច្បាស់លាស់អំពីវដ្តនៃការអនុវត្តគណនេយ្យភាពសង្គមនៅឡើយ។ នៅពេលដែលត្រូវបានសួរថាតើដឹងអ្វីខ្លះពី Post-On ដែលបានបិទផ្សាយ ក្រុមប្រឹក្សា តំណាងមណ្ឌលសុខភាព និងតំណាងសាលាបឋមសិក្សាទាំងនោះថាមិនបានដឹងទេ ដោយឆ្លើយថា "*ខាងរដ្ឋបាលស្រុកយកមកបិទឲ្យ តែមិនដឹងថាព័ត៌មានPost-On នោះនិយាយអំពីអ្វីផង*"។ ជាងនេះទៅទៀតអ្នកផ្តល់សេវាទាំងនោះហាក់ដូចជាមិនដឹងថាខ្លួននឹងត្រូវធ្វើអ្វីបន្តទៀតទេបន្ទាប់ពីការបង្ហាញព័ត៌មានជូនព័ត៌មានដល់ប្រជាពលរដ្ឋ។

- **ការអនុវត្តនៅក្នុងស្រុកពាមរក៍ ខេត្តព្រៃវែង**

ការអនុវត្តគណនេយ្យភាពសង្គមនៅក្នុងស្រុកនេះគឺបានអនុវត្តនៅក្នុងឃុំពាមរក៍ និងមណ្ឌលសុខភាព និងសាលាបឋមសិក្សាចំណុះឃុំនេះ។ ឃុំពាមរក៍ មណ្ឌលសុខភាពពាមរក៍ និងបឋមសិក្សា ក្នុងដែនសមត្ថកិច្ចឃុំពាមរក៍នេះ បានបិទផ្សាយព័ត៌មាននៃ Post-On មានលក្ខណៈមានបច្ចុប្បន្នភាព និងទិន្នន័យមិនមានកំហុសបច្ចេកទេសឡើយបន្ទាប់ពីបញ្ចេញពីប្រព័ន្ធទិន្នន័យក្នុងការផលិតPost-On ហើយទិន្នន័យដែលរដ្ឋបាលស្រុកផលិតជាPost-On ហើយ តែងត្រូវបានបញ្ជាក់សួរឡើងវិញពីអ្នកផ្តល់សេវាទាំងបី ដើម្បីធានាភាពត្រឹមត្រូវមុនធ្វើការបិទផ្សាយ។

រីឯចំណេះដឹងនៃអ្នកអនុវត្តគណនេយ្យភាពសង្គម នៅក្នុងតំបន់គោលដៅនេះមានលក្ខណៈល្អប្រសើរ ដែលអាចទទួលយកបាន គឺយល់ច្បាស់ពីជំហានទាំង ៣ នៃការអនុវត្តគណនេយ្យភាពសង្គមច្បាស់លាស់។ នៅពេលឆាប់ៗខាងមុខនេះពួកគេនឹងត្រៀមខ្លួនក្នុងការអនុវត្តជំហានទី២ ពោលគឺជំហានការត្រួតពិនិត្យរបស់ប្រជាពល រដ្ឋ។ ជារួមរដ្ឋបាលស្រុកពាមរក៍ ការិយាល័យសុខាភិបាលស្រុក និងការិយាល័យអប់រំស្រុក ឃុំពាមរក៍ មណ្ឌលសុខភាព និងសាលបឋមសិក្សាក្នុងដែនសមត្ថកិច្ចឃុំពាមរក៍នេះ មានកិច្ចសហការល្អក្នុងការអនុវត្តគណនេយ្យភាពសង្គមនេះ ព្រមទាំងមានកិច្ចសហការល្អជាមួយសង្គមស៊ីវិលនៅក្នុងមូលដ្ឋាន។ រដ្ឋបាលស្រុកពាមរក៍ បានរៀបចំផែនការអនុវត្តរួមគ្នាជាមួយអង្គការសង្គមស៊ីវិលនៅមូលដ្ឋានតាំងពីដើមឆ្នាំក្នុងការអនុវត្តវដ្តនៃគណនេយ្យភាពឲ្យបានពេញលេញ។ ទោះបីជាយ៉ាងណាក៏ដោយការបិទផ្សាយI4Cs នៅឃុំពាមរក៍នេះ ក៏ត្រូវបានធ្វើឡើងនៅតែកន្លែងផ្តល់សេវាប៉ុណ្ណោះ ពោលគឺនៅតែសាលាឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សាដែរ។

**២.) អំពីការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ និង៣.)ដំណើរការកសាងផែនការដែលមានស្រាប់**

ក្នុងជំហានទី២ និងទី៣ នេះ មានតែស្រុកពាមរក៍មួយគត់ដែលធ្លាប់បានដំណើររហូតដល់ការបង្កើតផែនការគណនេយ្យភាពរួម (JAAP) កាលពីឆ្នាំកន្លងមក និងមានគណៈកម្មាការJAAP ហើយអ្នកផ្តល់សេវាទាំងនោះ មានការពេញចិត្តនឹងការអនុវត្តការងារគណនេយ្យភាពសង្គម ដោយបានលើកឡើងថាការងារគណនេយ្យភាពសង្គមនេះបានផ្តល់ឱកាសឲ្យអ្នកផ្តល់សេវា និងទទួលសេវាមានឱកាសស្វែងយល់ពីគ្នាទៅវិញទៅមក និងផ្តល់ព័ត៌មានត្រលប់។ អ្នកផ្តល់សេវានៅឃុំពាមរក៍នេះ ក៏បានសំណូមពរដល់ថ្នាក់ជាតិ បន្តជួយគាំទ្របន្ថែម ដើម្បីឲ្យឃុំពាមរក៍ មណ្ឌលសុខភាព និងសាលាបឋមសិក្សា នៃតំបន់នេះ ក្លាយជាតំបន់គំរូក្នុងការអនុវត្តI-SAF។ ជាមួយគ្នានេះ ផែនការសកម្មភាពមួយចំនួនដែលបានលើកឡើងរួមគ្នាក្នុងJAAP ក៏ត្រូវបានដោះស្រាយផងដែរ។

ឃ.ការវិភាគ

ឆ្លងកាត់តាមការតាមការចុះបេសកកម្មនេះ ក្រុមការងារយល់ឃើញថា ការអនុវត្តសកម្មភាពគណនេយ្យភាពសង្គមនៅស្រុករមាសហែក និងស្រុកអូរាំងឳ នេះនៅមានកម្រិតនៅឡើយ ដោយមិនបានដឹងច្បាស់ពីតួនាទីភារកិច្ចរបស់ខ្លួនទាំងនៅថ្នាក់ស្រុក និងថ្នាក់ឃុំ ជាពិសេសជំហាននីមួយៗក្នុងការអនុវត្តឲ្យបានច្បាស់លាស់។ ម្យ៉ាងវិញទៀត ការងារគណនេយ្យភាពសង្គមនេះគឺជាកិច្ចការមួយថ្មីដែលទាមទារនូវពេលវេលារៀនសូត្របន្ថែមទៀត។

សព្វថ្ងៃនេះស្រុករមាសហែកមិនទាន់ទទួលបានថវិកាអនុវត្តពីខាងផ្នែកផ្គត់ផ្គង់នៅឡើយទេគឺមានតែផ្នែកតម្រូវការអនុវត្តគឺអង្គការស្តារកម្ពុជា ដែលវាអាចជាមូលហេតុមួយដែរ ដែលធ្វើឲ្យប្រសិទ្ធភាពនៃការអនុវត្តនៅមានកម្រិតដោយខ្វះការគាំទ្រពីផ្នែកផ្គត់ផ្គង់។

ចំពោះស្រុកពាមរក៍ ដែលការអនុវត្តគណនេយ្យភាពសង្គមមានភាពល្អប្រសើរអាចអនុវត្តរហូតដល់ការបង្កើត JAAP គឺដោយសារតែស្រុកគោលដៅនេះត្រូវបានជ្រើសរើសសាកល្បងតាំងពីផែនការយុទ្ធសាស្ត្រគណ នេយ្យភាពចាប់ផ្តើម ដូច្នេះរដ្ឋបាលស្រុកនេះពិតជារៀនសូត្របានយ៉ាងច្រើនតាមរយៈទ្រឹស្តី និងការអនុវត្តទាំងពីផ្នែកតម្រូវការ និងផ្នែកផ្គត់ផ្គង់។ អ្វីដែលសំខាន់ទៀតនោះ ស្រុកនេះបានសហការយ៉ាងល្អជាមួយផ្នែកតម្រូវការ ពោលគឺអង្គការសង្គមស៊ីវិលនៅមូលដ្ឋាន រហូតដល់រៀបចំផែនការរួមគ្នាក្នុងការអនុវត្តក្នុងរយៈពេលមួយឆ្នាំ។

ទោះបីយ៉ាងណាក៏ដោយ ស្រុកគោលដៅទាំង ៣ ដែលបានចុះត្រួតពិនិត្យ មិនត្រូវបានអនុវត្តការងារគណនេយ្យភាពសង្គមនៅគ្រប់ឃុំទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលផ្ទុយពីគោលដៅនៃផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ង. សេចក្តីសន្និដ្ឋាន

ជារួមការអនុវត្តគណនេយ្យភាពសង្គមនៅក្នុងស្រុករមាសហែក និងស្រុកអូរាំងឳនៅមិនទាន់មានភាពប្រសើរនៅឡើយទេទាំងរដ្ឋបាលស្រុក ឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សា ដែលទាមទារនៅការបណ្តុះបណ្តាលបន្ថែម និងការគាំទ្រដល់ផ្នែកផ្គត់ផ្គង់នៃស្រុកទាំងពីរនេះ។ រីឯស្រុកពាមរក៍ ដែលបានអនុវត្តបានប្រសើរនោះគឺដោយសារស្រុកទទួលបានការបណ្តុះបណ្តាលបានច្រើន ដោយត្រូវបានជ្រើសរើសអនុវត្តសាកល្បងដំបូងនៅពេលការងារគណនេយ្យសង្គមចាប់ផ្តើមដំណើរការ។

ជាមួយគ្នានេះផងដែរ ការអនុវត្តគណនេយ្យភាពសង្គមនៅតាមស្រុកទាំងបីខាងលើនេះ នៅមិនទាន់អនុវត្តនៅគ្រប់ឃុំក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឡើយ ដែលទាមទារនៅការជជែកគ្នារវាងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការដើម្បីដោះស្រាយបញ្ហានេះ។ ម្យាងវិញទៀត ការបិទផ្សាយ I4Cs ត្រូវបានធ្វើឡើងតែនៅក្នុងទីតាំងកន្លែងអ្នកផ្តល់សេវាតែប៉ុណ្ណោះ ដែលការផ្សព្វផ្សាយនេះមិនត្រូវបានធ្វើឡើងដោយទូលំទូលាយឡើយ។

ច. អនុសាសន៍

- ផ្តល់វគ្គបណ្តុះបណ្តាលបំប៉នជាថ្មីដល់រដ្ឋបាលស្រុក ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងការិយាល័យអប់រំស្រុក ឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សាស្តីពីការអនុវត្តគណនេយ្យភាពសង្គមឡើងវិញកាន់តែឆាប់កាន់តែល្អ ដើម្បីឲ្យបានមុនការអនុវត្តដំណើរការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋ(ពីខែឧសភា ដល់ខែកញ្ញា នៃឆ្នាំនីមួយៗ)។ ការផ្តល់វគ្គបំប៉ននេះមិនត្រូវធ្វើឡើងតែសម្រាប់តែស្រុករមាសហែក ខេត្តស្វាយរៀង និងស្រុកអូរាំងឳ ខេត្តត្បូងឃ្មុំនោះទេ គឺត្រូវធ្វើសម្រាប់គោលដៅកន្លងមកទាំងអស់ ដោយសារកិច្ចការងារគណនេយ្យភាពសង្គមគឺជាកិច្ចការមួយថ្មីដែលទាមនូវការពង្រឹងសមត្ថភាពឲ្យបានញឹកញាប់
- គួររៀបចំបញ្ចប់គោលការណ៍ណែនាំប្រតិបត្តិ (Operational Guideline) របស់ផ្នែកផ្គត់ផ្គង់ និងដាក់ឲ្យប្រើប្រាស់ ដើម្បីទុកជាជំនួយស្មារតីដល់អ្នកអនុវត្តផ្ទាល់ក្នុងការអនុវត្តជំហាននីមួយៗ និងឲ្យការអនុវត្តមានការឯកភាពគ្នា។

- បង្កើនការផ្តល់កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋដល់រដ្ឋបាលឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សា ដើម្បីអាចឲ្យអ្នកផ្តល់សេវាទាំងនោះអាចបិទនៅទីតាំងរបស់ខ្លួនផង និងនៅតាមទីប្រជុំជនផងយ៉ាងហោចណាស់ ២ ឈុត (Set) សម្រាប់ឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សានីមួយៗ។
- ប្រព័ន្ធទិន្នន័យតាមរយៈACCESS Program ត្រូវតែពិនិត្យឡើងវិញ។ ការរៀបចំប្រព័ន្ធទិន្នន័យ ដើម្បីផលិត Post-On តាមACCESS Program តែងមានកំហុសបច្ចេកទេស និងភាពខុសគ្នាពីកំព្យូទ័រមួយទៅកុំព្យូទ័រមួយ ដូច្នេះត្រូវរៀបចំប្រព័ន្ធនេះឡើងវិញដោយរៀបចំជាWeb-based Database។
- រដ្ឋបាលស្រុកនីមួយៗគួរតែរៀបចំផែនការដើមឆ្នាំរួមគ្នាជាមួយអង្គការសង្គមស៊ីវិលនៅមូលដ្ឋាន អំពីដំណើរការនៃការអនុវត្តគណនេយ្យភាពសង្គមក្នុងឆ្នាំនីមួយៗ ដែលវានឹងបង្ហាញការសហការគ្នាល្អរវាងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ និងជំរុញប្រសិទ្ធភាពនៃការអនុវត្ត។
- ចំពោះស្រុកគោលដៅចាស់ទាំង ២២ ហើយដែលក្នុងនោះ ៩ស្រុកមិនមានផ្នែកតម្រូវការអនុវត្តគួរតែផ្ទេរថវិកាពីស្រុកដែលមិនមានផ្នែកតម្រូវការអនុវត្តនោះ មកស្រុកដែលកំពុងមានផ្នែកតម្រូវការអនុវត្តដូចជាស្រុករមាសហែកជាដើម។
- ផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការនៅថ្នាក់ជាតិគួរជជែកគ្នាឡើងវិញអំពីបញ្ហាដែលស្រុកនីមួយៗមិនបានអនុវត្តនៅគ្រប់ឃុំ ដើម្បីរកដំណោះស្រាយសមស្របមួយ។
- ចំពោះតំបន់គោលដៅណាដែលបានអនុវត្តJAAP ល្អប្រសើរ ទាំងផ្នែកផ្គត់ផ្គង់ នឹងផ្នែកតម្រូវការគួរសហការចាប់ផ្តើមកត់ត្រាទុកនូវករណីសិក្សា(Case Study) ដើម្បីទុកជាការរៀនសូត្រសម្រាប់ការអនុវត្តបន្ត។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើនេះ សូមឯកឧត្តមមេត្តាជ្រាបជារបាយការណ៍ និងផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមឲ្យកាន់តែមានប្រសិទ្ធភាព។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ជ.ប្រធានអង្គភាព**

ជេដ្ឋ គីមជុង

បានឃើញ

30/06/15

ម៉ាន់ ចាំរើន